KPMG

# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## របាយការណ៍ហិរញ្ញវត្ថុ
## និង
## របាយការណ៍របស់សវនករ
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
និងរបាយការណ៍របស់សវនករឯករាជ្យ ដែលភ្ជាប់មកជាមួយ គឺជាការប្រែសំរួលជាភាសាខ្មែរ
ពីរបាយការណ៍ជាភាសាអង់គ្លេស ។ ក្នុងករណីមានភាពមិនស្របគ្នារវាងភាសាទាំងពីរ
ឯកសារជាភាសាអង់គ្លេស ត្រូវបានយកជាគោល ។

# ពត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ក្រុមហ៊ុន | **អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី** |
| ចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ | Co. 1698/03E |
| ទីស្នាក់ការ | អគារ មជ្ឈមណ្ឌលភ្នំពេញ បន្ទប់លេខ 191 ប្លុក F<br>កែងផ្លូវ សុធារស និងផ្លូវព្រះសីហនុ<br>សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន<br>រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| ម្ចាស់ភាគហ៊ុន | Concern Worldwide (Dublin)<br>Concern Worldwide (UK) |
| ក្រុមប្រឹក្សាភិបាល | លោក Thomas James O' Higgins ជាប្រធានក្រុមប្រឹក្សាភិបាល<br>លោក Pel Piseth ជាលេខាធិការ<br>លោក Howard Dalzell<br>លោក Paul Luchtenburg<br>លោក Peter Power<br>លោក Peter Baynard Smith<br>លោក Tip Janvibol<br>លោក Gerhard Bruckermann<br>លោក Tanmay Chetan<br>លោក Adam Mooney |
| សវនករ | ខេភីអឹមជី ខេមបូឌា ចំកាត់ |
| ធនាគារិកចំបង | ធនាគារ Acleda Bank Plc Ltd |

របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

## មាតិកា


| | | ទំព័រ |
|---|---|---|
| 1 | របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 |
| 2 | របាយការណ៍របស់សវនករឯករាជ្យ | 6 |
| 3 | តារាងតុល្យការ | 8 |
| 4 | របាយការណ៍លទ្ធផល | 9 |
| 5 | របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន | 10 |
| 6 | របាយការណ៍ចលនាសាច់ប្រាក់ | 11 |
| 7 | កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ | 13 |


---
របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានក្តីសោមនស្សរីករាយដាក់ជូនពិនិត្យនូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី ហៅកាត់ថា (“ក្រុមហ៊ុន” ឬ “អេ អឹម ខេ”) ដែលបានធ្វើសវនកម្មរួច សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008 ។

## សកម្មភាពចំបង

សកម្មភាពចំបងរបស់ អេ អឹម ខេ គឺ ផ្តល់សេវាមីក្រូហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋក្រីក្រកម្ពុជា ដែលមានសកម្មភាពសេដ្ឋកិច្ចតាមរយៈទីស្នាក់ការកណ្តាលនៅក្រុងភ្នំពេញ និងសាខាតាមបណ្តាខេត្តផ្សេងៗទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008 មានដូចខាងក្រោម:

| | ពាន់រៀល |
|---|---|
| ប្រាក់ចំណេញមុនដកពន្ធ | 4,999,614 |
| ពន្ធលើប្រាក់ចំណេញ | (975,156) |
| ប្រាក់ចំណេញក្រោយដកពន្ធ | 4,024,458 |

## ទុនបំរុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបំរុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍លទ្ធផល និងតារាងតុល្យការរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការណ៍ ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាវិធានការណ៍ទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យ ត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលមានការជឿជាក់ថា រាល់ឥណទានដែលបានដឹងថាមិនអាចទារបាន ត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើងសំរាប់ឥណទានដែលជាប់សង្ស័យ ។

របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (បន្ត)

### ឥណទានអាក្រក់ និងជាប់សង្ស័យ (បន្ត)

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាលឱ្យចំនួននៃការលុបបំបាត់ចោលឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានលក្ខណៈមិនគ្រប់គ្រាន់រហូតដល់កំរិតជាសារវន្តណាមួយនោះទេ ។

### ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍លទ្ធផល និងតារាងតុល្យការរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការណ៍ ដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្ត លើកលែងបំណុលចេញដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលមានតម្លៃមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចលក់បានជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវនោះទេ ។

### វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រ ដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងទ្រព្យអកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ ។

### បំណុលយថាហេតុ និងទ្រព្យអកម្មផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមានៈ

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬទ្រព្យអកម្មផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល 12 ខែ បន្ទាប់ពីថ្ងៃបញ្ចប់នៃការិយបរិច្ឆេទនឹងមានការប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់ ។

---
របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (បន្ត)

### ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានរៀបរាប់នៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឱ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ ។

### ប្រការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទនេះ មិនមានការប៉ះពាល់ជាសារវ័ន្តណាមួយដល់ចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវ័ន្ត និងមិនប្រក្រតីនោះទេ ។

ក្រុមប្រឹក្សាភិបាលក៏មានយោបល់ផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវ័ន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

### ព្រឹត្តិការណ៍ចាប់តាំងពីការិយបរិច្ឆេទនៃតារាងតុល្យការ

ពុំមានព្រឹត្តិការណ៍សំខាន់ៗ កើតមានឡើងនៅក្រោយថ្ងៃការិយបរិច្ឆេទនៃតារាងតុល្យការ ដែលតំរូវឱ្យមានការបង្ហាញ ឬការធ្វើ និយ័តកម្មនោះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

### ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបានបម្រើការចាប់តាំងពីថ្ងៃចេញរបាយការណ៍ចុងក្រោយមាន:

- លោក Thomas James O’ Higgins ជាប្រធានក្រុមប្រឹក្សាភិបាល
- លោក Pel Piseth ជាលេខាធិការ
- លោក Howard Dalzell ជានាយក
- លោក Paul Luchtenburg ជានាយក
- លោក Peter Power ជានាយក
- លោក Peter Baynard Smith ជានាយក
- លោក Tip Janvibol ជានាយក
- លោក Gerhard Bruckermann ជានាយក
- លោក Tanmay Chetan ជានាយក
- លោក Adam Mooney ជានាយក

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (បន្ត)

### ក្រុមប្រឹក្សាភិបាល (បន្ត)

សមាជិកទាំងអស់ មិនមែនជាសមាជិកប្រតិបត្តិនៃក្រុមប្រឹក្សាភិបាលនោះទេ លើកលែងតែលោក Paul Luchtenburg ដែលមានតួនាទីជានាយកប្រតិបត្តិរបស់ក្រុមហ៊ុន ។

### ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ពុំមានសមជិកក្រុមប្រឹក្សាភិបាលណាម្នាក់ កាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុននោះទេ ។ ពុំមានការរៀបចំណាមួយដែលមានក្រុមហ៊ុនជាគូភាគី ក្នុងគោលបំណងជួយដល់សមាជិករបស់ក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៏នៅក្នុងក្រុមហ៊ុន ឬពីក្រុមហ៊ុនដទៃទៀតទេ ។

### អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានការរៀបចំណាមួយដែលមានក្រុមហ៊ុនជាគូភាគីមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៏ដោយមធ្យោបាយនៃការទិញយកភាគហ៊ុន ឬលិខិតបំណុល ឬពីក្រុមហ៊ុនដទៃទៀតទេ ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃឆ្នាំកន្លងទៅ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៏ណាមួយ (ក្រៅអំពីអត្ថប្រយោជន៏ដែលបានរួមបញ្ចូលនៅក្នុងចំនួនបរិលាភសរុបទទួលបានដោយសមាជិកក្រុមប្រឹក្សាភិបាល ដូចបានបង្ហាញនៅក្នុងរបាយការណ៏ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធណាមួយជាមួយនឹងក្រុមហ៊ុន ដែលសមាជិកក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៏ ផ្នែកហិរញ្ញវត្ថុជាសំខាន់នោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៏ហិរញ្ញវត្ថុ ។

### ដើមទុន

នៅក្នុងការិយបច្ឆេទ ក្រុមហ៊ុនបានធ្វើការបង្កើនដើមទុនដែលបានចុះបញ្ជីរួចពី 10,149 លានរៀល ទៅ 34,069 លានរៀល តាមរយៈការបង្វែរឥណទាន និងការប្រាក់ពី Concern Worldwide (Dublin) ដែលមានចំនួនទឹកប្រាក់សរុប 23,606 លានរៀល ។ ការបង្កើនដើមទុននេះត្រូវបានអនុញ្ញាតិដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី 16 ខែ កក្កដា ឆ្នាំ 2008 ។

# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (បន្ត)

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីចង្អុលបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008 និងលទ្ធផលនៃការធ្វើប្រតិបត្តិការ និងស្ថានភាពចលនាសាច់ប្រាក់ សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវៈ

(ក) អនុម័តគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តឱ្យបានជាប់លាប់ ។

(ខ) អនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឬបើមានការផ្លាស់ប្តូរពីនេះដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ គឺត្រូវធ្វើការកំណត់បង្ហាញ ពន្យល់ឱ្យបានច្បាស់លាស់ និងកំណត់បរិមាណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

(គ) រក្សាទុកបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធិភាព ។

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានករណីមិនសមរម្យក្នុងការសន្មត់ថា ក្រុមហ៊ុននឹងមិនបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគតដែលគិតទុកជាមុន ។

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធិភាពលើរាល់សេចក្តីសំរេច ដែលមានសារៈសំខាន់ទាំងអស់ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការ ហើយត្រូវធ្វើឱ្យប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុខាងលើ ។

*ចុះហត្ថលេខាដោយយោងទៅលើសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលៈ*



លោក Thomas James O'Higgins

ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទីៈ 17/3/09

KPMG Cambodia Ltd
No 2 Street 208
Sangkat Beoung Prolit
Khan 7 Makara, Phnom Penh
Kingdom of Cambodia

Telephone +855 (23) 216 899
Fax +855 (23) 217 279
Internet www.kpmg.com

# របាយការណ៍របស់សវនករឯករាជ្យ
# ជូនចំពោះម្ចាស់ភាគហ៊ុនរបស់
# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន **អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី** ហៅកាត់ថា ("ក្រុមហ៊ុន" ឬ "អេ អឹម ខេ") ដែលរួមមាន តារាងតុល្យការ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008 និងរបាយការណ៍លទ្ធផល របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន និងរបាយការណ៍ចលនាសាច់ប្រាក់សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងសេចក្តីសង្ខេបលើគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងកំណត់សំគាល់ផ្សេងៗ ដែលបានបង្ហាញនៅ ទំព័រទី 8 ដល់ទី 61 ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងរបស់ក្រុមហ៊ុន មានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការទទួលខុសត្រូវនេះរួមមាន ការបង្កើត ការអនុវត្ត និងការរក្សារនូវប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការរៀបចំ និងការបង្ហាញនូវភាពពិត និង ត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ឱ្យជៀសផុតពីកំហុសឆ្គងជាសារវ័ន្តដោយសារការក្លែងបន្លំ ឬការភាន់ច្រឡំ ការជ្រើសរើស និងការអនុវត្តគោលនយោបាយគណនេយ្យសមស្រប និងការប្រើប្រាស់គណនេយ្យប៉ាន់ស្មាន ដែលសមស្របទៅតាមកាលៈទេសៈ ។

## ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺធ្វើការបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុ ផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មកម្ពុជា និងស្តង់ដារសវនកម្មអន្តរជាតិ ។ ស្តង់ដារទាំងនេះតម្រូវឱ្យយើងខ្ញុំ អនុវត្តទៅតាមតម្រូវការក្រមសីលធម៌ដែលពាក់ព័ន្ធ ដោយគំរោងផែនការ និងធ្វើសវនកម្ម ដើម្បីទទួលបាននូវអំណះអំណាងយ៉ាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុ ពុំមានកំហុសឆ្គងជាសារវ័ន្តឡើយ ។

ការធ្វើសវនកម្ម រួមមានការអនុវត្តនូវបណ្តានីតិវិធីត្រួតពិនិត្យ ដើម្បីទទួលបាននូវភស្តុតាងដែលទាក់ទងទៅនឹងបរិមាណទឹកប្រាក់ និងកំណត់បង្ហាញទាំងឡាយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការជ្រើសរើសនីតិវិធីទាំងនេះគឺផ្អែកទៅលើការវិនិច្ឆ័យរបស់យើងខ្ញុំ ដែលរួមមានការប៉ាន់ប្រមាណទៅលើហានិភ័យដែលមានផលប៉ះពាល់ជាសារវ័ន្តលើរបាយការណ៍ហិរញ្ញវត្ថុបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ ។ នៅក្នុងការប៉ាន់ប្រមាណហានិភ័យទាំងនោះ យើងខ្ញុំធ្វើការពិចារណាទៅលើការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ពន្ធ័ទៅនឹងការរៀបចំ និងការបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីធ្វើសវនកម្មឱ្យសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិយោបល់ទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។

ការធ្វើសវនកម្ម ក៏រួមមានការវាយតម្លៃទៅលើភាពសមស្របនៃគោលការណ៍គណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មានសំខាន់ៗ ដែលធ្វើឡើងដោយគណៈគ្រប់គ្រង ព្រមទាំងការវាយតម្លៃលើភាពគ្រប់គ្រាន់នៃការបង្ហាញនៅក្នុងរបាយកាណ៍ហិរញ្ញវត្ថុ ។

យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សំរាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់យើងខ្ញុំ ។

**មតិយោបល់**

ជាមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន **អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី** នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008 ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពចលនាសាច់ប្រាក់របស់ក្រុមហ៊ុនសំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយស្របទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំនិងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលមានភ្ជាប់មកជាមួយ ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកដើម្បីធ្វើការកំណត់បង្ហាញតែប៉ុណ្ណោះ ។ យើងខ្ញុំបានធ្វើសវនកម្មទៅលើការប្តូរនូវរូបិយប័ណ្ណនេះ ហើយជាមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ ដែលបានបង្ហាញជាប្រាក់រៀល ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកដោយផ្អែកលើមូលដ្ឋានដែលបានបង្ហាញ នៅក្នុងកំណត់សំគាល់ទី 4 នៃរបាយការណ៍ហិរញ្ញវត្ថុ ។

**តំណាងក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា ចំកាត់**

Craig McDonald
*Audit Partner*

រាជធានីភ្នំពេញ ថ្ងៃទី 17 ខែ មីនា ឆ្នាំ 2009

របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

# អង្គការ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## តារាងតុល្យការ
## នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

| | | 2008 | | 2007 | |
|---|---|---|---|---|---|
| | កំណត់សំគាល់ | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 5 | 567,753 | 139,121 | 282,765 | 70,638 |
| ប្រាក់បញ្ញើ និងប្រាក់តំកល់ នៅធនាគារនានា | 6 | 17,506,021 | 4,289,640 | 4,511,587 | 1,127,052 |
| ប្រាក់បញ្ញើតាមច្បាប់ | 7 | 1,725,463 | 422,804 | 529,446 | 132,262 |
| ឥណទានផ្តល់ដល់អតិថិជន | 8 | 94,568,950 | 23,172,985 | 41,373,587 | 10,335,645 |
| គណនីត្រូវទទួលផ្សេងៗ | 9 | 2,254,719 | 552,492 | 864,441 | 215,948 |
| ទ្រព្យសកម្មអរូបិយ | 10 | 597,444 | 146,396 | 25,371 | 6,338 |
| អចលនទ្រព្យ និងទ្រព្យសំភារៈ | 11 | 2,916,598 | 714,677 | 1,731,705 | 432,602 |
| ពន្ធពន្យារជាទ្រព្យសកម្ម | 12 | 335,516 | 82,214 | - | - |
| **សរុបទ្រព្យសកម្ម** | | 120,472,464 | 29,520,329 | 49,318,902 | 12,320,485 |
| **ទ្រព្យអកម្ម និងមូលនិធិម្ចាស់ហ៊ុន** | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 13 | 630,609 | 154,523 | 517,393 | 129,251 |
| គណនីត្រូវទូទាត់ទៅម្ចាស់ហ៊ុន | 14 | 155,082 | 38,001 | 308,031 | 76,950 |
| ប្រាក់កម្ចី | 15 | 71,327,793 | 17,478,018 | 31,839,077 | 7,953,804 |
| ទ្រព្យអកម្មផ្សេងៗ | 16 | 3,431,502 | 840,849 | 758,393 | 189,456 |
| សំវិធានធនសំរាប់ពន្ធលើ ប្រាក់ចំណេញ | 17 | 1,066,524 | 261,339 | 552,357 | 137,986 |
| សំវិធានធនសំរាប់ប្រាក់សោធននិវត្តន៍ | 18 | 1,206,083 | 295,536 | 633,563 | 158,272 |
| សរុបទ្រព្យអកម្ម | | 77,817,593 | 19,068,266 | 34,608,814 | 8,645,719 |
| **មូលនិធិម្ចាស់ហ៊ុន** | | | | | |
| ដើមទុន | 19 | 34,069,250 | 8,348,260 | 10,148,925 | 2,535,330 |
| ប្រាក់ចំណេញរក្សាទុក | | 8,585,621 | 2,103,803 | 4,561,163 | 1,139,436 |
| សរុបមូលនិធិម្ចាស់ហ៊ុន | | 42,654,871 | 10,452,063 | 14,710,088 | 3,674,766 |
| **សរុបទ្រព្យអកម្ម និង មូលនិធិម្ចាស់ហ៊ុន** | | 120,472,464 | 29,520,329 | 49,318,902 | 12,320,485 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# អេ.អិន.ហ្ស៊ី បាងហ្គិ (កម្ពុជា) អិលធីឌី

## របាយការណ៍លទ្ធផល
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

| | | 2008 | | 2007 | |
|---|---|---|---|---|---|
| | កំណត់សំគាល់ | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណូលពីការប្រាក់ | 20 | 24,875,427 | 6,095,424 | 11,033,452 | 2,756,296 |
| ចំណាយលើការប្រាក់ | 21 | (4,341,115) | (1,063,738) | (501,155) | (125,195) |
| ចំណូលសុទ្ធពីការប្រាក់ | | 20,534,312 | 5,031,686 | 10,532,297 | 2,631,101 |
| ចំណូលប្រតិបត្តិការផ្សេងៗ | 22 | 1,011,762 | 247,920 | 1,334,338 | 333,334 |
| ចំណូលប្រតិបត្តិការ | | 21,546,074 | 5,279,606 | 11,866,635 | 2,964,435 |
| ចំណាយលើថ្លៃឈ្នួល និងកំរៃជើងសារ | 23 | (860,542) | (210,866) | (445,591) | (111,314) |
| ចំណាយប្រតិបត្តិការ និងចំណាយផ្សេងៗ | 24 | (14,881,466) | (3,646,524) | (7,265,860) | (1,815,104) |
| សំវិធានធនសំរាប់ឥណទាន អាក្រក់ និងជាប់សង្ស័យ | 8 | (804,452) | (197,121) | (217,976) | (54,453) |
| ប្រាក់ចំណេញមុនដកពន្ធ | | 4,999,614 | 1,225,095 | 3,937,208 | 983,564 |
| ពន្ធលើប្រាក់ចំណេញ | 17 | (975,156) | (238,950) | (641,844) | (160,340) |
| ប្រាក់ចំណេញសុទ្ធសំរាប់ ការិយបរិច្ឆេទ | | 4,024,458 | 986,145 | 3,295,364 | 823,224 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

| | ដើមទុន<br>ពាន់រៀល | ប្រាក់ចំណេញរក្សាទុក<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|
| សមតុល្យនាថ្ងៃទី 1 ខែ មករា ឆ្នាំ 2007 | 10,148,925 | 1,265,799 | 11,414,724 |
| ប្រាក់ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ | - | 3,295,364 | 3,295,364 |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2007 | 10,148,925 | 4,561,163 | 14,710,088 |
| ការបង្វែរប្រាក់កម្ចីពីម្ចាស់ហ៊ុន | 23,920,325 | - | 23,920,325 |
| ប្រាក់ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ | - | 4,024,458 | 4,024,458 |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008 | 34,069,250 | 8,585,621 | 42,654,871 |
| (ស្មើនឹងដុល្លារអាមេរិក) | 8,348,260 | 2,103,803 | 10,452,063 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

# អេស្ភរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## របាយការណ៍ចលនាសាច់ប្រាក់
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

| | កំណត់សំគាល់ | 2008 ពាន់រៀល | 2008 ដុល្លារអាមេរិក | 2007 ពាន់រៀល | 2007 ដុល្លារអាមេរិក |
|---|---|---|---|---|---|
| **ចលនាសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពប្រតិបត្តិការ | 25 | (51,671,473) | (12,661,473) | (15,269,882) | (3,814,610) |
| **ចលនាសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសកម្មអរូបិយ | | (641,813) | (157,269) | - | - |
| ការទិញអចលនទ្រព្យ និងទ្រព្យសំភារៈ | | (1,999,358) | (489,918) | (1,181,719) | (295,208) |
| សាច់ប្រាក់ទទួលបានពីការលក់អចលនទ្រព្យ និងទ្រព្យសំភារៈ | | - | - | 14,466 | 3,614 |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | | (2,641,171) | (647,187) | (1,167,253) | (291,594) |
| **ចលនាសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | | 64,497,927 | 15,804,441 | 19,507,218 | 4,873,150 |
| ការទូទាត់សងប្រាក់កម្ចី | | (1,088,886) | (266,818) | (316,080) | (78,961) |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន | | 63,409,041 | 15,537,623 | 19,191,138 | 4,794,189 |
| **ការកើនឡើងនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | 9,096,397 | 2,228,963 | 2,754,003 | 687,985 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ** | | 4,794,352 | 1,197,690 | 2,040,349 | 502,921 |
| លំអៀងពីការប្តូររូបិយប័ណ្ណ | | - | (22,892) | - | 6,784 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | 26 | 13,890,749 | 3,403,761 | 4,794,352 | 1,197,690 |

របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## របាយការណ៍ចលនាសាច់ប្រាក់ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

### ប្រតិបត្តិការមិនទាក់ទងនឹងសាច់ប្រាក់សំខាន់ៗ

នៅក្នុងការិយបរិច្ឆេទ ក្រុមហ៊ុនមានប្រតិបត្តិការមិនទាក់ទងនឹងសាច់ប្រាក់សំខាន់ៗ ដូចខាងក្រោម:

| | 2008 | | 2007 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ការបង្វែរប្រាក់កម្ចីទៅជាដើមទុន | 23,920,325 | 5,861,388 | - | - |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

### 1. រចនាសម្ព័ន្ធ និងសកម្មភាពចំបង

ក្រុមហ៊ុន **អង្គរមីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី** ហៅកាត់ថា (“ក្រុមហ៊ុន” ឬ “អេ អឹម ខេ”) គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានអាជ្ញាប័ណ្ណ និងបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមការចុះបញ្ជីពាណិជ្ជកម្មលេខ Co. 1698/03E នៅថ្ងៃទី 30 ខែ មេសា ឆ្នាំ 2003 ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត ។ សកម្មភាពចំបងរបស់ អេ អឹម ខេ គឺ ផ្តល់សេវាមីក្រូហិរញ្ញវត្ថុ ដល់ប្រជាពលរដ្ឋក្រីក្រកម្ពុជា ដែលមានសកម្មភាពសេដ្ឋកិច្ចតាមរយៈទីស្នាក់ការកណ្តាលនៅក្រុងភ្នំពេញ និងសាខាតាមបណ្តាខេត្តផ្សេងៗទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ Concern Worlwide (Dublin) កាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនចំនួន 99.99 % ។

ក្រុមហ៊ុននេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1999 ដោយ Concern Worldwide, Cambodia (“CWC”) ជាកម្មវិធីធនាគារ ពន្លឺថ្មី ហៅកាត់ថា (“TPT”) ។ ទ្រព្យសកម្ម ទ្រព្យអកម្ម និងជំនួយសរុបទាំងអស់របស់ TPT ត្រូវបានផ្ទេរកម្មសិទ្ធិទៅឱ្យក្រុមហ៊ុន នៅថ្ងៃទី 1 ខែ កក្កដា ឆ្នាំ 2003 ក្រោមទំរង់ជាការបោះភាគហ៊ុន ។ អេ អឹម ខេ បានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មនៅថ្ងៃផ្ទេរសិទ្ធិទ្រព្យសកម្មនោះ ។

អេ អឹម ខេ ផ្តល់សេវាកម្មឥណទានដល់គ្រួសារក្រីក្រក្នុងខេត្តចំនួនម្ភៃ គឺ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកណ្តាល ខេត្តតាកែវ ខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តរតនះគីរី និងខេត្តមណ្ឌលគីរី ។ អេ អឹម ខេ មានគោលការណ៏សំខាន់ៗ ដូចខាងក្រោមៈ

- អេ អឹម ខេ នឹងផ្តល់សេវាមីក្រូហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋកម្ពុជាក្រីក្រ ដែលមានគោលការណ៏ហិរញ្ញវត្ថុរឹងមាំនៅគ្រប់កំរិត ។

- អេ អឹម ខេ នឹងគោរពតាមគោលការណ៏បើកទូលាយ និងតម្លាភាពនូវគ្រប់ចំនុចទាំងអស់នៃការគ្រប់គ្រង និងប្រតិបត្តិការ ។

- អេ អឹម ខេ នឹងអភិវឌ្ឍន៏ដំណើរការ/សេវាកម្ម និងប្រកាន់ខ្ជាប់នូវអត្តចរិត និងស្តង់ដារ ដើម្បីធានាឱ្យបានការបំរើសង្គមប្រកបដោយប្រសិទ្ធិភាពខ្ពស់ ដោយរួមបញ្ចូលនូវការការពារអត្ថប្រយោជន៏របស់អតិថិជន ។

- អេ អឹម ខេ ជាស្ថាប័នរៀនសូត្រ ដែលការផ្លាស់ប្តូរ និងចែករំលែកពតិមានដ៏សមស្រប និងចូលរួមចំណែកក្នុងការអភិវឌ្ឍន៏ និងបណ្តុះបណ្តាលបុគ្គលិក ព្រមទាំងចូលរួមចំណែកក្នុងការអភិវឌ្ឍន៏គោលនយោបាយ និងប្រព័ន្ធ ។

ក្រុមហ៊ុនមានបុគ្គលិកចំនួន 566 នាក់ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008 (ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2007: 349 នាក់) ។

# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

## 2. មូលដ្ឋានគ្រឹះនៃការរៀបចំ

### (ក) របាយការណ៍នៃការអនុវត្តតាម

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងស្របតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា លេខ 7 អំពីការកំណត់បង្ហាញលើឧបករណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័តក្នុងឆ្នាំ 2007 និងត្រូវបានចាប់ផ្តើមដាក់ឱ្យប្រើប្រាស់សំរាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើម ឬបន្ទាប់ពីថ្ងៃទី 1 ខែ មករា ឆ្នាំ 2008 ។ ការអនុម័តនៃស្តង់ដារនេះ បានបង្កើនតំរូវការកំណត់បង្ហាញទៅលើឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែវាគ្មានផលប៉ះពាល់ដល់ប្រាក់ចំណេញដែលបានរាយការណ៍ ឬស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះទេ ។

### (ខ) មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើម ។

### (គ) រូបិយប័ណ្ណសំរាប់ការវាស់វែង និងការកំណត់បង្ហាញ

ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើរូបិយប័ណ្ណចំនួនបី គឺប្រាក់រៀល ប្រាក់ដុល្លារអាមេរិក និងប្រាក់បាតថៃ ។ គណៈគ្រប់គ្រងបានកំណត់ប្រាក់រៀលជារូបិយប័ណ្ណ សំរាប់ការវាស់វែង និងការកំណត់បង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន ហើយប្រតិបត្តិការឥណទានភាគច្រើន គឺធ្វើឡើងជាប្រាក់រៀល ។

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់រៀល ត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។ ទ្រព្យសកម្ម និងទ្រព្យអកម្មដែលជារូបិយប័ណ្ណផ្សេងទៀតក្រៅពីប្រាក់រៀល ក៏ត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើប្រាស់អត្រានាថ្ងៃតារាងតុល្យការ ។ ភាពលំអៀងពីការប្តូររូបិយប័ណ្ណដែលកើតមកពីការប្តូរនោះ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តំរូវឱ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មត់ ដែលប៉ះពាល់ដល់ការអនុវត្តនូវគោលការណ៍គណនេយ្យ និងចំនួននៃទ្រព្យសកម្ម ទ្រព្យអកម្ម ចំណូល និងចំណាយដែលបានរាយការណ៍ ។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ ។

### 2. មូលដ្ឋាននៃការរៀបចំ (បន្ត)

#### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (បន្ត)

ការប៉ាន់ស្មាន និងការសន្មត់ ត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែទៅលើគណនេយ្យប៉ាន់ស្មាន ត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងការិយបរិច្ឆេទដែលការប៉ាន់ស្មាននោះត្រូវបានត្រួតពិនិត្យឡើងវិញ និងនៅក្នុងការិយបរិច្ឆេទដែលផលប៉ះពាល់នោះនឹងកើតមានឡើងនាពេលអនាគត ។

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗខាងក្រោមនេះ ត្រូវបានអនុវត្តដោយក្រុមហ៊ុនក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ។ គោលនយោបាយទាំងអស់នេះក៏ត្រូវយកមកអនុវត្តផងដែរក្នុងការិយបរិច្ឆេទមុនៗ លើកលែងតែចំនុចណាដែលបានបញ្ជាក់ ។

#### (ក) ឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្ម និងទ្រព្យអកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមានសាច់ប្រាក់ និងសាច់ប្រាក់សមមូល ការផ្តល់ឥណទាន ទ្រព្យសកម្មផ្សេងៗ ប្រាក់បញ្ញើ និងទ្រព្យអកម្មផ្សេងៗ ។ គោលនយោបាយគណនេយ្យលើការទទួលស្គាល់ និងការវាយតម្លៃនូវសមាសធាតុទាំងនេះ ត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកពីគ្នា ។

#### (ខ) ពត៏មានជាផ្នែក

ក្រុមហ៊ុនធ្វើប្រតិបត្តិការក្នុងវង្វង់អាជីវកម្មរបស់ខ្លួន គឺសេវាមីក្រូហិរញ្ញវត្ថុ និងស្ថិតនៅក្នុងដែនភូមិសាស្ត្រតែមួយ គឺព្រះរាជាណាចក្រកម្ពុជា ។

#### (គ) មូលដ្ឋាននៃការប្រមូលផ្តុំ

របាយការណ៍ហិរញ្ញវត្ថុរួមមាន របាយការណ៍ហិរញ្ញវត្ថុរបស់ទីស្នាក់ការកណ្តាល និងសាខាតាមបណ្តាខេត្តចំនួន ម្ភៃ គឺ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកណ្តាល ខេត្តតាកែវ ខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តរតនះគីរី និងខេត្តមណ្ឌលគីរី បន្ទាប់ពីការលុបបំបាត់ចោលនូវសមតុល្យ និងប្រតិបត្តិការអន្តរសាខា ។

# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត )

#### (ឃ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ និងសមតុល្យធនាគារ ប្រាក់បញ្ញើគ្មានកាលកំណត់ និងការវិនិយោគរយៈពេលខ្លី ដែលអាចប្តូរជាសាច់ប្រាក់បានក្នុងរយៈពេល 3 ខែ ឬតិចជាងនាពេលទិញ និងដែលអាចប្តូរជាសាច់ប្រាក់ ដែលមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ ។

#### (ង) ប្រាក់បញ្ញើ និងប្រាក់តំកល់នៅធនាគារនានា

ប្រាក់បញ្ញើ និងប្រាក់តំកល់នៅធនាគារនានា ត្រូវបានកត់ត្រាតាមតម្លៃដើម ។

#### (ច) ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន ដែលបានបង្ហាញនៅក្នុងតារាងតុល្យការ ត្រូវបានកត់ត្រាតាមថ្លៃដើមដែលនៅសល់ ហើយដកចេញចំនួនដែលបានលុបចោល សំវិធានធនជាក់លាក់ និងសំវិធានធនទូទៅ ។

ភាពគ្រប់គ្រាន់នៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ ត្រូវបានវាយតម្លៃដោយគណៈគ្រប់គ្រងរៀងរាល់ខែ ។ លក្ខខណ្ឌទាំងឡាយត្រូវបានពិចារណាក្នុងការវាយតម្លៃទៅលើភាពគ្រប់គ្រាន់នៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យមានដូចជា ទំហំនៃឥណទាន បទពិសោធន៍នៃការខាតបង់កន្លងទៅ លក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្ន និងផលប៉ះពាល់ផ្សេងៗដល់អតិថិជន ស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន និងស្ថានភាពជាក់ស្តែងនៃឥណទានធៀបនឹងលក្ខខណ្ឌដែលបានចែងនៅក្នុងកិច្ចសន្យា ។

#### (ឆ) សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ

ដើម្បីអនុវត្តទៅតាមការណែនាំរបស់ធនាគារជាតិនៃកម្ពុជា សំវិធានធនជាក់លាក់លើឥណទានអាក្រក់ និងជាប់សង្ស័យ ត្រូវបានធ្វើតែទៅលើឥណទានដែលបានចាត់ទុកថាឥតដំណើរការ ដែលត្រូវធ្វើឡើងដូចខាងក្រោម:

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| ឥណទានរយៈពេលខ្លី (តិចជាងមួយឆ្នាំ): | | |
| ឥណទានក្រោមស្តង់ដារ | ពី 31 ទៅ 60 ថ្ងៃ | 10% |
| ឥណទានជាប់សង្ស័យ | ពី 61 ទៅ 90 ថ្ងៃ | 30% |
| ឥណទានបាត់បង់ | លើសពី 90 ថ្ងៃ | 100% |

# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

**(ឆ) សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ (បន្ត)**

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| ឥណទានរយៈពេលវែង (លើសពីមួយឆ្នាំ): | | |
| ឥណទានក្រោមស្តង់ដារ | ពី 31 ទៅ 180 ថ្ងៃ | 10% |
| ឥណទានជាប់សង្ស័យ | ពី 181 ទៅ 360 ថ្ងៃ | 30% |
| ឥណទានបាត់បង់ | លើសពី 360 ថ្ងៃ | 100% |

សំវិធានធនជាក់លាក់ ត្រូវបានគណនាជាភាគរយលើឥណទានដែលនៅសល់ នៅពេលដែលវាត្រូវបានចាត់ថ្នាក់ដោយមិនរាប់បញ្ចូលនូវការប្រាក់បង្គរទុកឡើយ ហើយត្រូវបានចាត់ជាចំណាយ ។ ការប្រាក់លើឥណទានមិនដំណើរការ មិនត្រូវបានបង្គរទេ ។

បន្ថែមលើសំវិធានធនជាក់លាក់ដែលបានគណនាខាងលើ សំវិធានធនទូទៅលើឥណទានអាក្រក់ និងជាប់សង្ស័យត្រូវបានធ្វើឡើងតាមអត្រា 1% នៃឥណទានដំណើរការដែលនៅសល់នាចុងការិយបរិច្ឆេទ ក្រៅពីឥណទានផ្តល់ដល់បុគ្គលិក ។

ឥណទានត្រូវបានលុបចោលហើយទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផល នៅពេលដែលឥណទានមិនទាន់សងហួសពីកាលកំណត់រយៈពេលមួយឆ្នាំ ។ ឥណទានលុបចោលត្រូវបានដកចេញពីឥណទានផ្តល់ដល់អតិថិជន និងដកចេញពីសំវិធានធន សំរាប់ឥណទានបាត់បង់ ។

***ឥណទានហួសកាលកំណត់***

យោងទៅតាមប្រកាសលេខ ធ7-00-51ប្រក ចុះថ្ងៃទី 17 ខែ កុម្ភៈ ឆ្នាំ 2000 ដោយធនាគារជាតិនៃកម្ពុជា ឥណទានហួសកាលកំណត់ គឺជាសមតុល្យឥណទានសរុប ដែលចំនួនប្រាក់ដើម ឬការប្រាក់របស់ឥណទាននោះបានហួសកាលកំណត់ លើកលែងតែកាលកំណត់សងរបស់ប្រាក់ដើម ឬការប្រាក់ត្រូវបានកែប្រែ ។

សំវិធានធននឹងត្រូវធ្វើការគណនាតាមភាគរយនៃចំនួនសមតុល្យសរុប នៅពេលដែលឥណទាននោះត្រូវបានចាត់ថ្នាក់ លើកលែងតែការប្រាក់បង្គរ ។ សំវិធានធន នឹងត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន និងត្រូវទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលរៀងរាល់ខែ នៅពេលដែលឥណទានត្រូវបានចាត់ថ្នាក់ក្រោមក៏រិតស្តង់ដារ ។ ការវិភាគឥណទានហួសកាលកំណត់មានក្នុងកំណត់សំគាល់លេខ 8 ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

### (ឆ) សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ (បន្ត)

ឥណទានដែលមិនអាចទារបាន ឬចំណែកនៃឥណទានដែលបានចាត់ថ្នាក់ជាឥណទានអាក្រក់ត្រូវបានលុបបំបាត់ចោលនៅពេលដែលអ្នកគ្រប់គ្រងវិនិច្ឆ័យឃើញថា ពុំមានសង្ឃឹមនឹងទារបាននូវឥណទានទាំងនោះមកវិញទេ បន្ទាប់ពីបានពិចារណាទៅលើការវាយតម្លៃវត្ថុបញ្ចាំដែលនៅសល់បើសិនមាន ។

ការប្រមូលបានមកវិញនូវឥណទាន ដែលបានលុបបំបាត់ចោលពីពេលមុន ត្រូវបានបង្ហាញជាការដកបន្ថយពីចំណាយលើសំវិធានធនសំរាប់ឥណទានអាក្រក់ និងជាប់សង្ស័យ ។

### (ជ) គណនីត្រូវទទួលផ្សេងៗ

គណនីត្រូវទទួលផ្សេងៗត្រូវបានកត់ត្រាតាមតំលៃរំពឹងថាអាចប្រមូលមកវិញបាន ។ ការប៉ាន់ស្មានត្រូវបានធ្វើឡើងសំរាប់គណនីត្រូវទទួលដែលជាប់សង្ស័យ ដោយផ្អែកតាមការត្រួតពិនិត្យនៃចំនួនដែលនៅសល់ចុងឆ្នាំ ។

### (ឈ) ទ្រព្យសកម្មអរូបិយ

ទ្រព្យសកម្មអរូបិយ ត្រូវបានកំណត់ដោយតម្លៃដើមដករំលោះបង្គរនិងឱនភាពនៃតម្លៃបង្គរប្រសិនបើមាន ។ តម្លៃទ្រព្យសកម្មអរូបិយ ត្រូវបានកាត់បន្ថយដោយប្រើមូលដ្ឋានរំលោះថយចុះជាលំដាប់តាមអត្រា 50% ក្នុងមួយឆ្នាំ ។

### (ញ) អចលនទ្រព្យ និងទ្រព្យសំភារៈ

(i) អចលនទ្រព្យ និងទ្រព្យសំភារៈ ត្រូវបានកត់ត្រាតាមតម្លៃដើមដកនូវរំលោះបង្គរ និងការខាតបង់នៃឱនភាពតម្លៃបង្គរ ប្រសិនបើមាន ។ នៅពេលដែលធាតុនៃទ្រព្យសម្បត្តិរួមបញ្ចូលនូវសមាសធាតុសំខាន់ៗ ដែលមានអាយុកាលកំណត់ប្រើប្រាស់ខុសៗគ្នា អចលនទ្រព្យទាំងនោះត្រូវបានចាត់ទុកជាធាតុផ្សេងគ្នា នៃអចលនៈទ្រព្យ និងទ្រព្យសំភារៈ ។

(ii) រំលោះលើអចលនទ្រព្យ និងទ្រព្យសំភារៈ ត្រូវបានបញ្ចូលជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល ដោយផ្អែកលើមូលដ្ឋានរំលោះថយចុះជាលំដាប់ ផ្អែកតាមពេលវេលាប្រើប្រាស់របស់អចលនទ្រព្យនីមួយៗ ។ អត្រារំលោះប្រចាំឆ្នាំ មានដូចខាងក្រោម:

| | |
|---|---|
| យានយន្ត | 25% |
| ម៉ូតូ | 25% |
| កុំព្យូទ័រ និងសំភារៈការិយាល័យ | 50% |

# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

#### (ញ) អចលនទ្រព្យ និងទ្រព្យសំភារៈ (បន្ត)

(iii) ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃអចលនទ្រព្យ និងទ្រព្យសំភារៈ ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានរួមបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យសកម្ម នៅពេលដែលទ្រព្យសកម្មនេះមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតដល់ក្រុមហ៊ុនលើសពីស្តង់ដារដើម ។ រាល់ការចំណាយបន្ទាប់ផ្សេងទៀត ត្រូវបានទទួលស្គាល់ជាបន្ទុកចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង ។

(iv) ចំណេញ ឬខាតពីការបោះចោល ឬការលក់ចេញនៃអចលនទ្រព្យ និងទ្រព្យសំភារៈណាមួយ ត្រូវបានកំណត់ដោយភាពខុសគ្នារវាងប្រាក់ចំណូលសុទ្ធពីការលក់ និងតម្លៃយោងនៃទ្រព្យសម្បត្តិនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលនៅថ្ងៃបោះចោល ឬលក់ចេញ ។

(v) អចលនទ្រព្យ និងទ្រព្យសំភារៈដែលបានដករំលោះអស់ហើយ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុ រហូតដល់ថ្ងៃដែលអចលនទ្រព្យទាំងនោះត្រូវបានលក់ ឬលុបបំបាត់ចោល ។

(vi) តម្លៃយោងនៃអចលនទ្រព្យ និងទ្រព្យសំភារៈ ត្រូវបានត្រួតពិនិត្យឡើងវិញចំពោះឱនភាពនៃតម្លៃ នៅពេលដែលមានការគូសបញ្ជាក់ណាមួយឱ្យដឹងថា អចលនទ្រព្យនោះចាំបាច់ត្រូវបន្ថយតម្លៃ ។ ឱនភាពនៃតម្លៃ ត្រូវបានវាស់វែងដោយប្រៀបធៀបតម្លៃយោងរបស់ទ្រព្យសកម្មជាមួយតម្លៃដែលអាចប្រមូលបានវិញ ។ ការខាតបង់លើការថយចុះនៃតម្លៃ ត្រូវបានចាត់ចូលជាបន្ទុកចំណាយក្នុងរបាយការណ៍លទ្ធផល ។

#### (ដ) ឱនភាពនៃទ្រព្យសកម្ម

(i) ទ្រព្យសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃនាការិយបរិច្ឆេទនៃការធ្វើរបាយការណ៍ ដើម្បីកំណត់ថាតើមានភស្តុតាងណាមួយដែលបង្ហាញថា ឱនភាពអាចកើតមានឡើង ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវចាត់ទុកថាមានឱនភាពក្នុងករណីដែលអាចបង្ហាញថា មានហេតុការណ៍មួយឬច្រើនជះឥទ្ធិពលអវិជ្ជមានទៅលើចលនាសាច់ប្រាក់នាពេលអនាគតនៃទ្រព្យសកម្មនោះ ។ ករណីនេះ មិនត្រូវបានប្រើប្រាស់សំរាប់ឥណទាន និងបុរេប្រទាន ដែលត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកនៅក្នុងកំណត់សំគាល់ 3 (ច) ។

ការខាតបង់លើឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានគណនាដោយផ្អែកលើភាពខុសគ្នារវាងតម្លៃនាពេលអនាគតដោយធ្វើការបញ្ចុះតម្លៃតាមអត្រាការប្រាក់ប្រសិទ្ធភាព ។

រាល់ទ្រព្យសកម្មសំខាន់ៗ ត្រូវបានត្រួតពិនិត្យទៅលើឱនភាពនៃតម្លៃ តាមទ្រព្យសកម្មនិមួយៗ ។ ទ្រព្យសកម្មដែលនៅសល់ ត្រូវបានវាយតម្លៃជារួមសំរាប់ទ្រព្យសកម្ម ដែលមានហានិភ័យឥណទានស្រដៀងគ្នា ។

# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

**(ជ) ឱនភាពនៃទ្រព្យសកម្ម (បន្ត)**

(i) ទ្រព្យសកម្មហិរញ្ញវត្ថុ (បន្ត)

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវដកចេញប្រសិនបើការដកចេញអាចពាក់ព័ន្ធជាមួយនឹងព្រឹត្តការណ៍ ដែលកើតឡើងក្រោយពី ការទទួលស្គាល់ការខាតបង់ពីឱនភាព ។

(ii) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានត្រួតពិនិត្យនៅរាល់ការិយបរិច្ឆេទ នៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីកំណត់ថាតើមានកត្តា ដែលនាំឱ្យមានឱនភាពឬទេ ។ ក្នុងករណីដែលមានកត្តាទាំងនោះកើតឡើងការប៉ាន់ស្មានតម្លៃ ដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ត្រូវបានធ្វើឡើង ។

តម្លៃ ដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺផ្អែកលើតម្លៃ ដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃទីផ្សារដកចំណាយលក់ចេញ ។ ក្នុងការវាយតម្លៃលើតម្លៃប្រើប្រាស់សាច់ប្រាក់ រំពឹងថានឹងទទួលបាននាពេលអនាគត ត្រូវបានបញ្ចុះទៅតម្លៃបច្ចុប្បន្ន ដោយប្រើប្រាស់អត្រាការប្រាក់មុនដកពន្ធ ដែលឆ្លុះបញ្ចាំងតម្លៃទីផ្សារផ្អែកលើតម្លៃនៃពេលវេលា និងហានិភ័យជាក់លាក់សំរាប់ទ្រព្យសកម្មទាំងនោះ ។ សំរាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាពនៃតម្លៃទ្រព្យសកម្ម ត្រូវបានដាក់បញ្ចូលគ្នាទៅក្រុមតូចៗ នៃទ្រព្យសកម្ម ដែលអាចបង្កើតសាច់ប្រាក់ពីការបន្តប្រើប្រាស់ ដែលមិនពឹងផ្អែកខ្លាំងលើលំហូរចូលនៃសាច់ប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត (“ឯកតាបង្កើតសាច់ប្រាក់”) ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់មានចំនួនលើសពីតម្លៃ ដែលអាចប្រមូលមកវិញបាន ។ ការខាតបង់ពីឱនភាពនៃតម្លៃ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

**(ឋ) ប្រាក់បញ្ញើរបស់អតិថិជន**

ប្រាក់បញ្ញើរបស់អតិថិជន ត្រូវបានកត់ត្រាតាមតម្លៃនៃប្រាក់តំកល់ ។

**(ឌ) ប្រាក់កម្ចី**

ប្រាក់កម្ចី ត្រូវបានកត់ត្រាតាមតម្លៃដើម ។

## អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

#### (ឍ) សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងតារាងតុល្យការនៅពេលដែលក្រុមហ៊ុនមាននូវកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកិច្ចសន្យា ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីពេលមុន និងមានលទ្ធភាព ដែលតម្រូវឱ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈជាសារវ័ន្ត សំវិធានធន ត្រូវបានគេកំណត់ដោយការបញ្ចុះតម្លៃចលនាសាច់ប្រាក់ ដែលរំពឹងទុកនាពេលអនាគត នៅអត្រាមុនបង់ពន្ធដែលវាឆ្លុះបញ្ចាំងពីការប៉ាន់ស្មានទីផ្សារបច្ចុប្បន្ន នៃតម្លៃពេលវេលានៃប្រាក់កាស និងដោយសមស្របទៅនឹងហានិភ័យជាក់លាក់នៃទ្រព្យអកម្ម ។

#### (ណ) សំវិធានធនសំរាប់ប្រាក់សោធននិវត្តន៍

សំវិធានធនសំរាប់ប្រាក់សោធននិវត្តន៍ ត្រូវបានគណនាតាមមូលដ្ឋានសមាមាត្រ ដោយគិតតាមអត្រាបៀវត្សមួយខែ សំរាប់រាល់ការបំពេញការងារបានរយៈពេលមួយឆ្នាំ ។ កាតព្វកិច្ចទាំងនេះ ត្រូវបង់តាមលក្ខខណ្ឌដូចខាងក្រោម:

(i) និយោជិកនឹងទទួលបានប្រាក់សោធននិវត្តន៍ពេញលេញ នៅពេលដែលនិយោជិកដល់អាយុកាលចូលនិវត្តន៍មានអាយុ 60 ឆ្នាំ ឬនិយោជិកត្រូវបានរំសាយដោយក្រុមហ៊ុន ។

(ii) និយោជិកឈប់មុនចូលនិវត្តន៍ នឹងទទួលអត្ថប្រយោជន៍ ដូចខាងក្រោម:

| **ចំនួននៃខែធ្វើការ** | **ប្រាក់សោធននិវត្តន៍ សរុបត្រូវផ្តល់ដល់និយោជិក** |
|---|---|
| តិចជាងប្រាំមួយខែ | មិនត្រូវបានផ្តល់ឱ្យ |
| ពីប្រាំមួយខែទៅមួយឆ្នាំ | ប្រាំពីរថ្ងៃនៃប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែម |
| លើសពីមួយឆ្នាំ | ដប់ប្រាំថ្ងៃជារៀងរាល់ឆ្នាំធ្វើការរហូតដល់ ប្រាំមួយខែនៃប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែម |

មិនមានការរក្សាទុកមូលនិធិដោយឡែកនោះទេ មានន័យថា ពុំមានការបំរុងទុកមូលនិធិដោយឡែកក្នុងគណនីធនាគារដែលមានការប្រាក់ ឬទ្រព្យសកម្មផ្សេងទៀតឡើយ ។

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

#### (ត) ការទទួលស្គាល់ប្រាក់ចំណូល និងចំណាយ

ចំណូលការប្រាក់ ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានបង្គរ ។ នៅពេលដែលឥណទានមួយក្លាយជាឥណទានមិនដំណើរការ ការកត់ត្រាការប្រាក់ថាជាចំណូល ត្រូវបានព្យួរទុក ហើយត្រូវទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានសាច់ប្រាក់ ។ ចំណូលពីការប្រាក់ ត្រូវបានធ្វើការគណនាដោយប្រើវិធីសាស្ត្រសមតុល្យថយចុះលើសមតុល្យឥណទាន ដែលនៅសល់ប្រចាំខែ ។

កំរៃសេវាកម្មឥណទាន ត្រូវបានទទួលស្គាល់ជាចំណូល នៅពេលដែលទឹកប្រាក់ឥណទានត្រូវបានផ្តល់ដល់អតិថិជន ។ កំរៃសេវាកម្មឥណទាន ត្រូវបានគណនាដោយប្រើប្រាស់ប្រាក់ដើម និងអត្រាកំរៃសេវាកម្ម ។

ចំណាយត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរ ។

#### (ថ) ប្រតិបត្តិការជួល

ថ្លៃឈ្នួលក្នុងបែបផែនជាការជួលប្រតិបត្តិការ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលតាមវិធីសាស្ត្ររំលោះថេរទៅតាមថេរវេលានៃការជួល ។

#### (ទ) ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញ លើការចំណេញ ឬខាតប្រចាំឆ្នាំ រួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល លើកលែងតែក្នុងករណីដែលវាទាក់ទងទៅនឹងសមាសធាតុដែលត្រូវទទួលស្គាល់ជាផ្នែកមួយនៃមូលនិធិម្ចាស់ហ៊ុន ។ ក្នុងករណីនេះ វាក៏ត្រូវបានកំណត់បង្ហាញថាជាផ្នែកមួយនៃមូលនិធិម្ចាស់ហ៊ុនផងដែរ ។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងទុកថា ត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅថ្ងៃតារាងតុល្យការ ជាមួយនឹងនិយ័តកម្មណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

ពន្ធពន្យារ ត្រូវបានកំណត់តាមវិធីសាស្ត្រទ្រព្យអកម្មនៃតារាងតុល្យការ លើភាពលំអៀងជាបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងទ្រព្យអកម្ម ក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃដែលប្រើក្នុងគោលបំណងនៃការគិតពន្ធ ។ តម្លៃនៃប្រាក់ពន្ធពន្យារដែលបានកំណត់នោះ គឺផ្អែកលើលក្ខណៈនៃការជឿជាក់នឹងទទួលបាន ឬការទូទាត់ដែលនឹងកើតឡើងរវាងតម្លៃយោងនៃទ្រព្យសកម្ម និងទ្រព្យអកម្ម ដោយប្រើអត្រាពន្ធកំណត់នៅថ្ងៃតុល្យការ ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

### (ខ) ពន្ធលើប្រាក់ចំណេញ (បន្ត)

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់តែក្នុងករណីអាចនឹងកើតមានឡើងលើប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដែលអាចប្រើប្រាស់ជាមួយនឹងទ្រព្យសកម្ម ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានកាត់បន្ថយក្នុងករណីដែលវាមិនអាចកើតឡើងនូវអត្ថប្រយោជន៍នៃពន្ធដែលពាក់ព័ន្ធ ដែលអាចនឹងប្រើប្រាស់បាន ។

### (ឍ) សម្ព័ន្ធញាតិ

ភាគីដែលត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិ ប្រសិនបើភាគីនោះ មានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោល ឬមានឥទ្ធិពលជាខ្លាំងទៅលើភាគីមួយទៀត ក្នុងការធ្វើសេចក្តីសំរេចហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬផ្ទុយមកវិញ បើក្រុមហ៊ុន និងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬក៏មានឥទ្ធិពលជាខ្លាំង ។ សម្ព័ន្ធញាតិអាចជារូបវន្តបុគ្គល ឬនិតិបុគ្គល និងរួមបញ្ចូលនូវរូបវន្តបុគ្គលនៃសមាជិកគ្រួសារដែលជិតស្និទ្ធក៏ត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិផងដែរ ។

នៅក្រោមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និយមន័យរបស់សម្ព័ន្ធញាតិ រួមបញ្ចូលផងដែរនូវភាគីដែលកាន់កាប់ភាគហ៊ុនដោយផ្ទាល់ ឬដោយប្រយោលយ៉ាងតិច 10% នៃដើមទុនធនាគារ ឬនៃសិទ្ធិបោះឆ្នោត និងរាប់បញ្ចូលនូវរូបវន្តបុគ្គលណាម្នាក់ដែលរួមចំណែកក្នុងការអភិបាលកិច្ច ការដឹកនាំ ការគ្រប់គ្រង ឬការរៀបចំ និងការអនុវត្តនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ។

## 4. ការប្តូររូបិយប័ណ្ណពីប្រាក់រៀលទៅជាដុល្លារអាមេរិក

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់រៀល ។ ការប្តូររូបិយប័ណ្ណពីប្រាក់រៀលទៅជាដុល្លារអាមេរិក គឺធ្វើឡើងសំរាប់ជាការបង្ហាញប៉ុណ្ណោះ ដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការប្រកាសដោយ ធនាគារជាតិនៃកម្ពុជា នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008 ដែល 1 ដុល្លារអាមេរិក ស្មើនឹង 4,081 រៀល (2007 : 4,003 រៀល) ។ តួលេខជាប្រាក់ដុល្លារអាមេរិកនេះគឺសំរាប់ជាការបង្ហាញតែប៉ុណ្ណោះ ហើយមិនត្រូវបានយកមកបកស្រាយថាតួលេខប្រាក់រៀល ត្រូវបានប្តូរ ឬនឹងត្រូវបានប្តូរជាដុល្លារអាមេរិក នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រា ប្តូរប្រាក់ផ្សេងទៀតនោះឡើយ ។

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

## 5. សាច់ប្រាក់ក្នុងដៃ

| | 2008 | | 2007 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ទីស្នាក់ការកណ្តាល | 12,214 | 2,993 | 15,865 | 3,963 |
| សាខានានានៅតាមខេត្ត | | | | |
| បន្ទាយមានជ័យ | 70,873 | 17,367 | 47,944 | 11,977 |
| បាត់ដំបង | 26,494 | 6,492 | 12,926 | 3,229 |
| កំពង់ចាម | 13,787 | 3,378 | 3,581 | 895 |
| កំពង់ឆ្នាំង | 34,010 | 8,334 | 12,669 | 3,165 |
| កំពង់ស្ពឺ | 49,941 | 12,237 | 21,549 | 5,383 |
| កំពង់ធំ | 19,342 | 4,740 | 22,504 | 5,622 |
| កណ្តាល | 30,039 | 7,361 | 4,531 | 1,132 |
| ក្រចេះ | 7,815 | 1,915 | 10,575 | 2,642 |
| ឧត្តរមានជ័យ | 18,158 | 4,449 | 27,711 | 6,922 |
| ព្រះវិហារ | 61,313 | 15,024 | 32,640 | 8,154 |
| ព្រៃវែង | 23,921 | 5,862 | 35,664 | 8,909 |
| ពោធិ៍សាត់ | 12,695 | 3,111 | 4,658 | 1,164 |
| សៀមរាប | 9,068 | 2,222 | 5,625 | 1,405 |
| ស្វាយរៀង | 37,517 | 9,193 | 12,710 | 3,175 |
| តាកែវ | 47,087 | 11,538 | 11,613 | 2,901 |
| កំពត | 24,320 | 5,959 | - | - |
| មណ្ឌលគិរី | 14,805 | 3,628 | - | - |
| រតនៈគិរី | 8,513 | 2,086 | - | - |
| ព្រះសីហនុ | 29,984 | 7,347 | - | - |
| ស្ទឹងត្រែង | 15,857 | 3,885 | - | - |
| | 567,753 | 139,121 | 282,765 | 70,638 |

## 5. សាច់ប្រាក់ក្នុងដៃ (បន្ត)

ចំនួនខាងលើ ត្រូវបានធ្វើការវិភាគដូចខាងក្រោម:

| | 2008 | | 2007 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| តាមរូបិយប័ណ្ណ: | | | | |
| ប្រាក់រៀលខ្មែរ | 456,619 | 111,889 | 195,497 | 48,838 |
| ប្រាក់បាតថៃ | 67,751 | 16,602 | 44,900 | 11,216 |
| ប្រាក់ដុល្លារអាមេរិក | 43,383 | 10,630 | 42,368 | 10,584 |
| | 567,753 | 139,121 | 282,765 | 70,638 |

## 6. ប្រាក់បញ្ញើ និងប្រាក់តំកល់នៅធនាគារនានា

| | | | | |
|---|---|---|---|---|
| ធនាគារ Acleda Bank Plc Ltd | 8,058,432 | 1,974,622 | 4,503,222 | 1,124,963 |
| ធនាគារជាតិនៃកម្ពុជា | 1,264,564 | 309,866 | 8,365 | 2,089 |
| ធនាគារពាណិជ្ជកម្មក្រៅប្រទេស | 8,183,025 | 2,005,152 | - | - |
| | 17,506,021 | 4,289,640 | 4,511,587 | 1,127,052 |

ចំនួនខាងលើ ត្រូវបានធ្វើការវិភាគដូចខាងក្រោម:

| | | | | |
|---|---|---|---|---|
| (ក) តាមកាលកំណត់: | | | | |
| ក្នុងរយៈពេល 1 ខែ | 12,098,696 | 2,964,640 | 4,511,587 | 1,127,052 |
| ក្នុងរយៈពេល 6 ខែ | 1,224,300 | 300,000 | - | - |
| ក្នុងរយៈពេល 24 ខែ | 4,183,025 | 1,025,000 | - | - |
| | 17,506,021 | 4,289,640 | 4,511,587 | 1,127,052 |

# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

### 6. ប្រាក់បញ្ញើ និងប្រាក់តំកល់នៅធនាគារនានា (បន្ត)

ចំនួនខាងលើ ត្រូវបានធ្វើការវិភាគដូចខាងក្រោមៈ

| | 2008 | | 2007 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| (ខ) តាមរូបិយប័ណ្ណៈ | | | | |
| ប្រាក់រៀលខ្មែរ | 5,157,620 | 1,263,813 | 3,407,097 | 851,136 |
| ប្រាក់បាតថៃ | 855,919 | 209,733 | 954,520 | 238,451 |
| ប្រាក់ដុល្លារអាមេរិក | 11,492,482 | 2,816,094 | 149,970 | 37,465 |
| | 17,506,021 | 4,289,640 | 4,511,587 | 1,127,052 |

(គ) តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)ៈ

| | 2008 | 2007 |
|---|---|---|
| ធនាគារ Acleda Bank Plc Ltd | 2% - 5% | 2% - 5% |
| ធនាគារពាណិជ្ជកម្មក្រៅប្រទេស | 0.75% | - |

### 7. ប្រាក់បញ្ញើតាមច្បាប់

| | 2008 | | 2007 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ប្រាក់បញ្ញើតាមច្បាប់ៈ | | | | |
| ដើមទុនចុះបញ្ជី | 1,703,463 | 417,413 | 507,446 | 126,766 |
| ប្រាក់បញ្ញើរបស់អតិថិជន | 22,000 | 5,391 | 22,000 | 5,496 |
| | 1,725,463 | 422,804 | 529,446 | 132,262 |

ប្រាក់បញ្ញើតាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-00-006ប្រក និង ធ7-06-209ប្រក ចំនួនប្រាក់បញ្ញើទាំងនេះត្រូវបានកំណត់ដោយភាគរយនៃដើមទុនដែលបានចុះបញ្ជីរបស់ក្រុមហ៊ុន និងប្រាក់បញ្ញើរបស់អតិថិជន ។

របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

### 7. ប្រាក់បញ្ញើតាមច្បាប់ (បន្ត)

ប្រាក់បញ្ញើតាមច្បាប់លើដើមទុនដែលបានចុះបញ្ជី គឺអាចដកមកវិញបាន នៅពេលដែលក្រុមហ៊ុនបញ្ចប់ប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងគ្មានប្រាក់បញ្ញើ ។ ប្រាក់បញ្ញើតាមច្បាប់លើប្រាក់បញ្ញើរបស់អតិថិជនប្រែប្រួល ដោយផ្អែកទៅលើកំរិតនៃប្រាក់បញ្ញើរបស់អតិថិជន ។

ចាប់ពីខែ កញ្ញា ឆ្នាំ 2006 ប្រាក់បញ្ញើតាមច្បាប់លើដើមទុនដែលបានចុះបញ្ជីរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ទទួលបានការប្រាក់តាមអត្រា 3% ក្នុង 1 ឆ្នាំ ។ ប្រាក់បញ្ញើតាមច្បាប់របស់អតិថិជនពុំទទួលបានការប្រាក់នោះទេ ។

### 8. ឥណទានផ្តល់ដល់អតិថិជន

| | 2008 | | 2007 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ធនាគារភូមិ: | | | | |
| សងជាបណ្តាក់ | 20,730,537 | 5,079,769 | 9,352,874 | 2,336,466 |
| សងនៅចុងវគ្គ | 23,281,576 | 5,704,870 | 14,877,513 | 3,716,591 |
| សងរំលោះដើមថេរ | 15,226,696 | 3,731,119 | 8,293,450 | 2,071,809 |
| ឥណទានឯកត្តជន: | | | | |
| ឥណទានបន្ទាន់-ចុងវគ្គ | 2,876,257 | 704,792 | 759,775 | 189,801 |
| សងរំលោះដើមថេរ | 32,514,796 | 7,967,360 | 7,975,231 | 1,992,314 |
| ឥណទានផ្តល់ដល់បុគ្គលិក | 961,777 | 235,672 | 535,826 | 133,856 |
| | 95,591,639 | 23,423,582 | 41,794,669 | 10,440,837 |
| សំវិធានធនសំរាប់ឥណទានអាក្រក់ និងជាប់សង្ស័យ | | | | |
| ជាក់លាក់ | (80,034) | (19,611) | (8,722) | (2,179) |
| ទូទៅ | (942,655) | (230,986) | (412,360) | (103,013) |
| | (1,022,689) | (250,597) | (421,082) | (105,192) |
| | 94,568,950 | 23,172,985 | 41,373,587 | 10,335,645 |
| ចំនួនអតិថិជនសរុប | 197,222 | | 122,654 | |

របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

### 8. ឥណទានផ្តល់ដល់អតិថិជន (បន្ត)

បំរែបំរួលនៃសំវិធានធនសំរាប់សំវិធានធនឥណទានអាក្រក់ និងជាប់សង្ស័យ មានដូចខាងក្រោម:

| | 2008 | | 2007 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| នាដើមការិយបរិច្ឆេទ | 421,082 | 105,192 | 217,246 | 53,548 |
| សំវិធានធនក្នុងការិយបរិច្ឆេទ | 804,452 | 197,121 | 217,976 | 54,453 |
| ការលុបបំបាត់ចោលក្នុង ការិយបរិច្ឆេទ | (193,024) | (47,298) | (23,136) | (5,780) |
| លំអៀងពីការប្តូររូបិយប័ណ្ណ | (9,821) | (4,418) | 8,996 | 2,971 |
| នាចុងការិយបរិច្ឆេទ | 1,022,689 | 250,597 | 421,082 | 105,192 |

ឥណទានផ្តល់ដល់អតិថិជន ត្រូវបានវិភាគដូចខាងក្រោម:

(ក) តាមកាលកំណត់:

| | 2008 ពាន់រៀល | 2008 ដុល្លារអាមេរិក | 2007 ពាន់រៀល | 2007 ដុល្លារអាមេរិក |
|---|---|---|---|---|
| ក្នុងរយៈពេល 1 ខែ | 1,194,155 | 292,613 | 1,054,880 | 263,523 |
| 1 ទៅ 3 ខែ | 10,073,069 | 2,468,285 | 7,405,307 | 1,849,939 |
| 3 ទៅ 12 ខែ | 30,101,560 | 7,376,025 | 27,035,362 | 6,753,775 |
| លើសពី 12 ខែ | 54,222,855 | 13,286,659 | 6,299,120 | 1,573,600 |
| | 95,591,639 | 23,423,582 | 41,794,669 | 10,440,837 |

(ខ) តាមរូបិយប័ណ្ណ:

| | 2008 ពាន់រៀល | 2008 ដុល្លារអាមេរិក | 2007 ពាន់រៀល | 2007 ដុល្លារអាមេរិក |
|---|---|---|---|---|
| ប្រាក់រៀលខ្មែរ | 86,964,416 | 21,309,585 | 34,300,576 | 8,568,718 |
| ប្រាក់បាតថៃ | 7,665,446 | 1,878,325 | 6,958,267 | 1,738,263 |
| ប្រាក់ដុល្លារអាមេរិក | 961,777 | 235,672 | 535,826 | 133,856 |
| | 95,591,639 | 23,423,582 | 41,794,669 | 10,440,837 |

# អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

## 8. ឥណទានផ្តល់ដល់អតិថិជន (បន្ត)

| | | 2008 | | 2007 | |
|---|---|---|---|---|---|
| | | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| (គ) | តាមផ្នែកសេដ្ឋកិច្ច: | | | | |
| | កសិកម្ម | 48,119,335 | 11,791,065 | 27,848,878 | 6,957,002 |
| | សំណង់ | 1,591,855 | 390,065 | 173,379 | 43,312 |
| | ក្រុមគ្រួសារ | 6,401,035 | 1,568,496 | 1,621,370 | 405,039 |
| | សេវាកម្ម | 1,386,633 | 339,778 | 1,226,096 | 306,294 |
| | ពាណិជ្ជកម្ម | 36,187,078 | 8,867,208 | 10,209,236 | 2,550,396 |
| | ដឹកជញ្ជូន | 435,205 | 106,642 | 272,700 | 68,124 |
| | ផ្សេងៗ | 1,470,498 | 360,328 | 443,010 | 110,670 |
| | | 95,591,639 | 23,423,582 | 41,794,669 | 10,440,837 |
| (ឃ) | តាមនិវាសនដ្ឋាន: | | | | |
| | និវាសនជន | 95,591,639 | 23,423,582 | 41,794,669 | 10,440,837 |
| (ង) | តាមទំនាក់ទំនងសម្ព័ន្ធញាតិ: | | | | |
| | អតិថិជនខាងក្រៅ | 94,629,862 | 23,187,910 | 41,258,843 | 10,306,981 |
| | ឥណទានផ្តល់ដល់បុគ្គលិក | 961,777 | 235,672 | 535,826 | 133,856 |
| | | 95,591,639 | 23,423,582 | 41,794,669 | 10,440,837 |

# អេស៊ីលីដា ម៉ៃក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ លីមីតធីត

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008

## 8. ឥណទានផ្តល់ដល់អតិថិជន (បន្ត)

| | 2008 | | 2007 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| (ច) តាមតំបន់: | | | | |
| ស្នាក់ការកណ្តាល | 961,777 | 235,672 | 535,826 | 133,856 |
| សាខានានានៅតាមបណ្តាខេត្ត | | | | |
| បន្ទាយមានជ័យ | 7,665,447 | 1,878,326 | 6,958,268 | 1,738,263 |
| បាត់ដំបង | 6,981,378 | 1,710,703 | 2,965,359 | 740,784 |
| កំពង់ចាម | 8,571,644 | 2,100,378 | 4,522,490 | 1,129,775 |
| កំពង់ឆ្នាំង | 4,080,110 | 999,782 | 1,787,103 | 446,441 |
| កំពង់ស្ពឺ | 8,169,384 | 2,001,809 | 5,597,883 | 1,398,422 |
| កំពង់ធំ | 8,150,610 | 1,997,209 | 3,692,383 | 922,404 |
| កណ្តាល | 5,048,896 | 1,237,171 | 1,239,269 | 309,585 |
| ក្រចេះ | 4,570,653 | 1,119,984 | 1,414,381 | 353,330 |
